# មេរៀនទី ១៥២៖
# ព្រះសន្យាថានឹងស្តារអ៊ីស្រាអែលឡើងវិញបន្ទាប់ពីការនិរទេសខ្លួន
## យេរេមា ២៩៖៤-១៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/INHFLHouxPU

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/KX6AxaApsp4

**គោលបំណង៖ ព្រះមានផែនការល្អសំរាប់យើង។**

**ខគម្ពីរចងចាំ៖ យេរេមា ២៩៖១១** *"ដ្បិតព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា អញស្គាល់សេចក្តី ដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្តីអាក្រក់ទេ គឺគិតឲ្យបានសេចក្តីសុខវិញ ដើម្បីដល់ចុងបំផុត ឲ្យឯងរាល់គ្នាបានសេចក្តីសង្ឃឹម។"*

**ចំរៀង** ( *យូធូបលីង* )៖
១. ព្រះទ្រង់ល្អណាស់ https://youtu.be/7hXZuD-Vd7A
២. ព្រះអម្ចាស់យើងល្អណាស់ https://youtu.be/JUMy8rZvqjY
៣. ទ្រង់មិនដែលខាន https://youtu.be/uVqBqBENPi4

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«ដណ្តើមស្ករគ្រាប់»**

សម្ភារៈដែលត្រូវការ៖ ស្ករគ្រាប់មួយចំនួនធំ

១.ឱ្យកុមារឈរជាជួរជាមួយដៃគូ។



២. គ្រូត្រូវដាក់ ស្ករគ្រាប់ ៤គ្រាប់ នៅលើឥដ្ឋ សម្រាប់ដៃគូនីមួយៗ

៣. គ្រូត្រូវនិយាយថា "ក្បាល ស្មា ជង្គង់ ចុងជើង" ប៉ុន្តែនៅពេលដែលគ្រូនិយាយពាក្យ "ស្ករគ្រាប់"។ ដូច្នេះដៃគូរត្រូវដណ្តើមស្ករគ្រាប់គ្នា។

៤. កុមារណាដែលមិនអាចយកស្ករគ្រាប់នោះបាន គេមិនអាចបន្តលេងល្បែងនេះបានទេ




៥. អ្នកឈ្នះទាំងអស់ត្រូវឈរជាជួរដោយចាប់ដៃគូរ និងលេងម្តងទៀត

៦. លេងល្បែងនេះរហូតនៅសល់កុមារតែម្នាក់ជាអ្នកឈ្នះ

៧.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា គឺដូចជាអ្នកឈ្នះល្បែងនេះអ៊ីចឹង គឺយើងត្រូវតែផ្តោត អារម្មណ៍ជានិច្ច ប្រសិនបើយើងផ្តោតលើព្រះ នោះទ្រង់នឹងបង្ហាញយើងពីផែនការដ៏ល្អដែលទ្រង់មាន សម្រាប់យើង។

**៤. ការណែនាំមេរៀន**

ពេលអ្នកថ្វាយបង្គំនៅព្រះវិហាររួច តើអ្នកមានគម្រោងធ្វើអ្វី? តើអ្នកមានគំរោងទៅផ្ទះវិញ ឬទៅលេងជាមួយមិត្តភក្តិរបស់អ្នក? តើអ្នកមានគំរោងអ្វីខ្លះសំរាប់អនាគតរបស់អ្នក? តើអ្នកចង់ក្លាយជាប៉ូលីស ? ជាគ្រូបង្រៀន? ជាគ្រូពេទ្យ? ជាកសិករ មែនទេ? ពេលខ្លះវាជាការពិបាកក្នុងការបង្កើតគំរោងសំរាប់

អនាគត ពីព្រោះអ្នកមិនអាចមើលឃើញពីអនាគតទេ។ ប៉ុន្តែព្រះជ្រាបដឹងពីអនាគតរបស់យើង ហើយព្រះអង្គមានផែនការដ៏ល្អសំរាប់យើង! ចូរយើងរៀនអំពី ផែនការដ៏ល្អដែលព្រះមានសំរាប់ ជនជាតិយូដា!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះបានប្រទាននូវច្បាប់យ៉ាងពិសេសសម្រាប់ជនជាតិយូដាដើម្បីឱ្យពួកគេប្រព្រឹត្តតាម ពីព្រោះព្រះអង្គស្រឡាញ់ និងចង់ជួយពួកគេឱ្យចេញឆ្ងាយពីការជ្រើសរើសអ្វីដែលមិនត្រឹមត្រូវ។ ប៉ុន្តែជនជាតិយូដាបានធ្វើខុសនឹងច្បាប់ទាំងនោះ ហើយពួកគេបានសំរេចចិត្តធ្វើអ្វីដែលពួកគេចង់ធ្វើតាមផ្លូវរបស់ខ្លួនទៅវិញ។ ពួក-គេមិនស្តាប់បង្គាប់ព្រះ ហើយព្រះអង្គបានព្រមានពួកគេជាច្រើនដង។ ទ្រង់បានមានបន្ទូលថា "ឯងត្រូវស្តាប់បង្គាប់អញ បើឯងមិនស្តាប់បង្គាប់អញ អញនឹងដាក់ទោសឯង។" ព្រះបានផ្តល់ឱកាសដល់ជនជាតិយូដាជាច្រើនដង ដើម្បីឱ្យពួកគេទទួលស្គាល់កំហុសរបស់ពួកគេ ចាប់ផ្តើមស្តាប់បង្គាប់ព្រះឡើងវិញ ប៉ុន្តែពួកគេនៅតែជ្រើសរើសមិនស្តាប់បង្គាប់ព្រះដដែល។

នៅទីបំផុតជនជាតិយូដាត្រូវបានដាក់ទោស។ ដោយមានប្រទេសដទៃបានចាប់ពួកគេធ្វើជាឈ្លើយ ហើយបញ្ជូនពួកគេទៅកន្លែងមួយហៅថាស្រុកបាប៊ីឡូន។ ពួកគេមិនចង់ចាកចេញពីផ្ទះរបស់ពួកគេទេ ប៉ុន្តែពួកគេត្រូវតែទៅ។ ដូច្នេះពួកគេបានរៀបចំសំពាយរបស់ពួកគេ ហើយចេញដំណើរទៅ។ ពួកគេរស់នៅស្រុកបាប៊ីឡូនអស់ រយៈពេល៧០ឆ្នាំជាង! នេះជារយៈពេលដ៏យូរ ដែលពួកគេរស់នៅឆ្ងាយពីផ្ទះរបស់ខ្លួន! ប៉ុន្តែព្រះមានផែនការពិសេសសំរាប់ពួកគេ។ ទោះបីជាពួកគេមិនស្តាប់បង្គាប់ទ្រង់ក៏ដោយ ក៏ព្រះនៅតែស្រឡាញ់ពួកគេ ដូចជាទ្រង់ស្រឡាញ់អ្នកដូច្នេះដែរ។

ព្រះគម្ពីរបានប្រាប់យើងថា ព្រះប្រាប់ទៅជនជាតិយូដាថា ទ្រង់មានផែនការដ៏ល្អសំរាប់ពួកគេ ហើយថាពួកគេនឹងមានអនាគតល្អ និងមានក្តីសង្ឃឹម។ ព្រះមានបន្ទូលថា ជនជាតិយូដានឹងបានត្រឡប់ទៅផ្ទះវិញ ហើយព្រះបានមានបន្ទូលថា ទ្រង់នឹងប្រទានឲ្យគេគ្រប់យ៉ាងដែលពួកគេធ្លាប់មានពីមុន! សាកស្រមៃបន្តិចមើលថាជនជាតិយូដាត្រូវមានអារម្មណ៍បែបណាពេលដែលពួកគេគេអាចត្រឡប់ទៅផ្ទះរបស់ពួកគេវិញបន្ទាប់ពីបានរស់នៅកន្លែងដែលគេចាប់ពួកគេធ្វើជាឈ្លើយអស់រយៈពេល៧០ឆ្នាំជាង។ ពួកគេបានសរសើរដំកើងព្រះ ហើយអរព្រះគុណព្រះដែលបានអត់ទោសឲ្យពួកគេ និងស្រឡាញ់ពួកគេ។

សេចក្តីស្រឡាញ់របស់ព្រះសំរាប់យើងគឺគ្រប់ល័ក្ខ ហើយជ្រាលជ្រៅ។ ទោះបីជាយើងបះបោរ និងមិនស្តាប់បង្គាប់ព្រះក៏ដោយ យើងអាចប្រាកដថាព្រះចង់ស្តារពួកយើងឡើងវិញ ហើយប្រទាននូវការល្អៗដល់យើងផងដែរ។ ព្រះមានផែនការល្អសំរាប់យើង ក៏ដូចជាទ្រង់មានផែនការល្អ សំរាប់ជនជាតិយូដាអញ្ចឹងដែរ។ យើងអាចមានអំណរដោយដឹងថាផែនការរបស់ព្រះនឹងប្រទានឲ្យយើងមានក្តីសង្ឃឹម និងមានអនាគតល្អ។

## ៦. សំនួរពិភាក្សា

១. តើព្រះបានប្រទានអ្វីឲ្យជនជាតិយូដាដើម្បីជួយរក្សាពួកគេចេញការធ្វើការសំរេចចិត្តខុស?
*(ព្រះបានប្រទានច្បាប់ឲ្យពួកគេ)*

២. តើជនជាតិយូដាបានធ្វើអ្វីខ្លះជាមួយនឹងច្បាប់ទាំងអស់នោះ? *(ពួកគេមិនបានធ្វើតាមច្បាប់ទាំងអស់នេះទេ ហើយក៏មិនស្តាប់បង្គាប់ព្រះដែរ)*

៣. តើអ្វីជាការដាក់ទោសសំរាប់ការដែលមិនគោរពតាមច្បាប់ និងមិនស្តាប់បង្គាប់ព្រះ?
*(បាប៊ីឡូនបានចូលមកហើយចាប់យកមនុស្សជាច្រើនធ្វើជាឈ្លើយ)*

៤. តើព្រះមានផែនការល្អអ្វីខ្លះសំរាប់ពួកគេ ទោះប្បីជាពួកគេមិនស្តាប់បង្គាប់ទ្រង់ក៏ដោយ? *(ផែនការរបស់ព្រះសំរាប់ពួកគេគឺនាំពួកគេទៅស្រុកយូដាវិញបន្ទាប់ពីបានធ្វើជាឈ្លើយអស់រយៈពេល៧០ឆ្នាំ ហើយធ្វើឲ្យពួកគេរីកចំរើនជាមួយសេចក្តីសង្ឃឹម និងមានអនាគត)*

៥. តើអ្នកគិតថាព្រះមានផែនការល្អអ្វីខ្លះសំរាប់អ្នក? *(សូមឲ្យកុមារឆ្លើយ)*

## ៧. ល្បែងកំសាន្ត «ព្រះគម្ពីរ»




សម្ភារៈដែលត្រូវការ៖ ហ្វឹត ឬដីស

១. គ្រូត្រូវគូររូបប្រអប់ធំៗពីរនៅលើឥដ្ឋដោយប្រអប់មួយសរសេរថា "ព្រះគម្ពីរសញ្ញាថ្មី"និង " ព្រះគម្ពីរសញ្ញាចាស់" នៅក្នុងប្រអប់មួយទៀត។

២. ឲ្យកុមារឈរនៅចន្លោះប្រអប់ទាំងពីរ

៣. គ្រូត្រូវជ្រើសរើស ១០កណ្ឌ ពីព្រះពម្ពីរសញ្ញាចាស់ និង ១០កណ្ឌសញ្ញាថ្មី គ្រូត្រូវប្រាប់កំណ្ឌ គម្ពីរដែលគាត់មានបានរើសមកនោះថាវាដកស្រង់ចេញពីព្រះគម្ពីរសញ្ញាចាស់ ឬសញ្ញាថ្មី។

៤. ប្រសិនបើគ្រូនិយាយឈ្មោះកំណ្ឌគម្ពីរមកពីសញ្ញាចាស់ កុមារត្រូវលោតទៅកាន់ប្រអប់សញ្ញាចាស់ និងនិយាយថា "ព្រះគម្ពីរសញ្ញាចាស់"។ ប្រសិនបើគ្រូនិយាយឈ្មោះកំណ្ឌគម្ពីរមកពីសញ្ញាថ្មី កុមារត្រូវលោតទៅកាន់ប្រអប់សញ្ញាថ្មី និងនិយាយថា "ព្រះគម្ពីរសញ្ញាថ្មី"។

៥. ប្រសិនបើកុមារលោតខុសប្រអប់នោះគេនិងចាញ់ល្បែងនេះ

៦. លេងល្បែងនេះរហូតនៅសល់កុមារតែ ៣ ទៅ ៥នាក់ជាអ្នកឈ្នះ

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ផែនការល្អៗរបស់ព្រះគឺមានសរសេរនៅក្នុងព្រះគម្ពីរទាំងអស់។ សូមចាំថាព្រះតែងតែមានផែនការល្អសម្រាប់អ្នកជានិច្ច!

## ៨. ខគម្ពីរចងចាំ

**យេរេមា ២៩៖១១** *"ដ្បិតព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា អញស្គាល់សេចក្តី ដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្តីអាក្រក់ទេ គឺគិតឲ្យបានសេចក្តីសុខវិញ ដើម្បីដល់ចុងបំផុតឲ្យឯងរាល់គ្នាបានសេចក្តីសង្ឃឹម។"*

**៩. ហត្ថកម្ម** ផាត់ពណ៌រូបភាព - "**ព្រះមានផែនការល្អសំរាប់យើង**"

១. អានគម្ពីរចងចាំជាមួយគ្នា ហើយឲ្យកុមារផាត់ពណ៌

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ប្រសិនបើយើងរស់នៅជាមួយព្រះយេស៊ូវជារៀងរាល់ថ្ងៃ ហើយរីកចម្រើនក្នុងសេចក្តីជំនឿរបស់យើង នោះព្រះយេស៊ូវបានផ្តល់ឱ្យយើងនូវការណែនាំផ្លូវ និងការកែតម្រូវសម្រាប់ជីវិតរបស់យើង។ ពេលដែលយើងឆ្លើយតបទៅនឹងការដឹកនាំរបស់ព្រះអង្គ យើងនឹងមានអំណរជាមួយនឹងសន្តិភាព និងសុវត្ថិភាពដែលមានតែព្រះទេដែលអាចផ្តល់ឲ្យយើងបាន។ ដូចជាជនជាតិយូដាបានរស់នៅជា ឈ្លើយក្រោមការគ្រប់គ្រងរបស់បាប៊ីឡូន។ វាហាក់ដូចជាគ្មានសង្ឃឹមសម្រាប់ពួកគេ។ ប៉ុន្តែ ព្រះបាន ប្រទានសេចក្តីសង្ឃឹមដល់ពួកគេដោយមានបន្ទូលថាពួកគេនឹងត្រឡប់ទៅស្រុកយូដាវិញក្រោយពី៧០ឆ្នាំ។ តើអ្នកកំពុងនៅកន្លែងណាក្នុងដំណើរជីវិតខាងព្រលឹងវិញ្ញាណរបស់អ្នក? តើអ្នកនៅផ្ទះ ឬនៅជាឈ្លើយ? ឆ្លុះបញ្ចាំងដំណើរជីវិតរបស់អ្នកជាមួយព្រះ ហើយទូលសុំព្រះជួយបង្ហាញផ្លូវ និងកែ តម្រូវជីវិតរបស់អ្នកនៅថ្ងៃនេះ។

# ព្រះមានផែនការល្អសំរាប់យើង



**យេរេមា ២៩:១១** *“ដ្បិតព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា អញស្គាល់សេចក្ដី
ដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្ដីអាក្រក់ទេ
គឺគិតឲ្យបានសេចក្ដីសុខវិញ ដើម្បីដល់ចុងបំផុត ឲ្យឯងរាល់គ្នាបានសេចក្ដីសង្ឃឹម។”*